## របៀបអានរបាយការណ៍សិស្ស

លទ្ធផលរបស់សិស្សនីមួយៗត្រូវបានបង្ហាញនៅលើរង្វាស់ខ្នាតតេស្ដវាយតម្លៃមួយ សម្រាប់មុខវិជ្ជានីមួយៗដែលធ្វើតេស្ដវាយតម្លៃ។

លទ្ធផលនៃការធ្វើតេស្ដវាយតម្លៃសមត្ថភាពសិក្សាសម្រាប់អក្ខរកម្ម និងលេខនព្វន្ដនៃសិស្សថ្នាក់ទី 3, ទី 5, ទី 7 និងទី 9 ត្រូវបានរាយការណ៍តាម រង្វាស់ខ្នាតមួយ ចាប់ពីលំដាប់ក្រុមទី 1 ដល់លំដាប់ក្រុមទី 10។ រង្វាស់ខ្នាតនៃសមិទ្ធិផលតំណាងកម្រិតជំនាញនិងការយល់ដឹងកាន់តែខ្លាំងឡើង ដែលបង្ហាញឲ្យឃើញនៅក្នុងការធ្វើតេស្ដវាយតម្លៃសមត្ថភាពសិក្សាទាំងឡាយ។

ឧទាហរណ៍៖ លទ្ធផលសម្រាប់ថ្នាក់ទី 3 ត្រូវបានរាយការណ៍នៅក្នុងលំដាប់ក្រុមទី 1 ដល់លំដាប់ក្រុមទី 6។




បើលទ្ធផលរបស់សិស្សស្ថិតនៅក្នុងទីនេះ វាមានន័យថា លទ្ធផលនេះមានកម្រិតលើសពីសមិទ្ធិផលដែលគេសង្ឃឹមសម្រេចបានសម្រាប់សិស្សថ្នាក់ទី 3។

ចំណុចនេះបង្ហាញនូវលទ្ធផលរបស់សិស្សនីមួយៗ។

រូបត្រីកោណខ្មៅបង្ហាញនូវលទ្ធផលមធ្យមទូទាំងប្រទេស សម្រាប់សិស្សថ្នាក់ទី 3។

ផ្នែកមានពណ៌ខ្ចីនេះបង្ហាញនូវទំហំសមិទ្ធិផលសម្រាប់សិស្សធុនកណ្ដាល 60% នៃសិស្សថ្នាក់ទី 3 នៅក្នុងប្រទេសអូស្ដ្រាលី។

សិស្សថ្នាក់ទី 3 ដែលទទួលលទ្ធផលក្នុងលំដាប់ក្រុមទី 1 ស្ថិតនៅក្រោមស្ដង់ដារជាតិទាបបំផុត។

### ព័ត៌មានបន្ថែម

ដើម្បីទទួលព័ត៌មានបន្ថែម និងការពិភាក្សាអំពីលទ្ធផលរបស់កូនលោកអ្នក សូមទាក់ទងគ្រូបង្រៀន ឬនាយកសាលារៀនរបស់កូនលោកអ្នក។

ដើម្បីទទួលព័ត៌មានបន្ថែមអំពីលទ្ធផលនិងរបាយការណ៍ NAPLAN សូមបើកមើលវិបសៃនៃកម្មវិធីជាតិធ្វើតេស្ដវាយតម្លៃសមត្ថភាពសិក្សា www.nap.edu.au ។


acara AUSTRALIAN CURRICULUM ASSESSMENT AND REPORTING AUTHORITY
www.acara.edu.au

NAP NATIONAL ASSESSMENT PROGRAM
www.nap.edu.au


# NAPLAN 2011

## កម្មវិធីជាតិធ្វើតេស្ដវាយតម្លៃសមត្ថភាពសិក្សា អក្ខរកម្ម និង លេខនព្វន្ដ

## ព័ត៌មានអំពីរបាយការណ៍សិស្សសម្រាប់មាតាបិតា



Khmer (Cambodian)


State Government Victoria
VICTORIAN CURRICULUM AND ASSESSMENT AUTHORITY

## កម្មវិធីជាតិធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សាតេស្តអក្ខរកម្ម និង លេខនព្វន្ត (NAPLAN)

នៅខែឧសភា ឆ្នាំនេះ សិស្សថ្នាក់ទី 3, ទី 5, ទី 7 និងទី 9 នៅទូទាំងប្រទេសអូស្ត្រាលី បានធ្វើតេស្តជាតិផ្នែកអក្ខរកម្មនិងលេខនព្វន្ត។ សិស្សជាងមួយលាននាក់មកពីសាលារៀនចំនួនជិត 10,000 នៅក្នុងប្រទេស បានចូលរួមក្នុងការធ្វើតេស្តជាតិនេះ។ របាយការណ៍ NAPLAN របស់កូនលោកអ្នក បង្ហាញលោកអ្នកថាតើកូនលោកអ្នកកំពុងទទួលលទ្ធផលយ៉ាងណាដែរ៖

- បើប្រៀបធៀបនឹងសិស្សឯទៀតនៅក្នុងប្រទេសអូស្ត្រាលី
- នៅក្នុងទំនាក់ទំនងជាមួយនឹងស្តង់ដារជាតិទាបបំផុត។

លទ្ធភាពក៏មានផងដែរដើម្បីដឹងនូវលទ្ធផលរបស់កូនលោកអ្នកក្នុងមួយរយៈពេល តាមរយៈការពិនិត្យមើលរបាយការណ៍ NAPLAN កាលគ្រាមុនទាំងឡាយ យ៉ាងណាមិញគេគួរតែមានការប្រុងប្រយ័ត្ន ដោយសារតែលទ្ធផលទាំងនោះ គឺសម្រាប់តែនៅពេលមួយគ្រានោះតែប៉ុណ្ណោះ ហើយប្រហែលជាមិនឆ្លុះបញ្ចាំងនូវសមត្ថភាពផ្សេងៗគ្នាដ៏ពេញលេញរបស់កូនលោកអ្នកឡើយ។ នៅឆ្នាំ 2011 រង្វាស់ខ្នាតថ្មីមួយអំពីការសរសេរ ត្រូវបានបង្កើតឡើងសម្រាប់ការសរសេរបញ្ចុះបញ្ចូល ដែលមិនអាច ប្រៀបធៀបបានជាមួយនឹងរង្វាស់ខ្នាតកាលគ្រាមុនអំពីការសរសេររឿងនិទានទេ ។

## តើការធ្វើតេស្ត NAPLAN វាយតម្លៃសមត្ថភាពសិក្សាអ្វីខ្លះ?

ការធ្វើតេស្តអក្ខរកម្ម វាស់ស្ទង់សមិទ្ធិផលរបស់សិស្សក្នុងការអាន សរសេរ និងក្បួនភាសា (ការប្រកបអក្សរ វេយ្យាករណ៍ និងវណ្ណយុត្តិ)។ ការធ្វើតេស្តលេខនព្វន្ត វាស់ស្ទង់សមិទ្ធិផលរបស់សិស្សក្នុងការធ្វើលេខ; ពីជគណិត មុខងារនិងលំនាំ; រង្វាស់រង្វាល់ ឱកាសនិងទិន្នន័យ; ហើយនិងលំហ។

## គោលបំណងនៃការធ្វើតេស្ត NAPLAN

លទ្ធផល NAPLAN នៅកម្រិតសាលារៀន ប្រព័ន្ធ និងជាតិ ត្រូវបានប្រើដើម្បីរកមើលដឹងចំណុចខ្លាំងនិងចំណុចខ្សោយនៃកម្មវិធីសិក្សា ហើយដើម្បីជួយកំណត់គោលដៅសម្រាប់កែលំអ។ នៅក្នុងថ្នាក់រៀន លទ្ធផល NAPLAN បង្ហាញគ្រូបង្រៀននូវសមិទ្ធិផលរបស់សិស្សដោយប្រៀបធៀបនឹងក្រុមទូលំទូលាយមួយនៃសិស្សទាំងឡាយនៅទូទាំងប្រទេសអូស្ត្រាលី។ របាយការណ៍របស់សិស្សនីមួយៗអាចត្រូវបានប្រើដើម្បីជាដំណើងសម្រាប់ការពិភាក្សារវាងមាតាបិតាជាមួយនឹងគ្រូបង្រៀន អំពីសមិទ្ធិផលនិងការរីកចម្រើនរបស់កូនលោកអ្នក។

ជាការសំខាន់ក្នុងការចងចាំថា លទ្ធផលទាំងឡាយឆ្លុះបញ្ចាំងចំណេះដឹងសិក្សារបស់សិស្សនៅនឹងពេលតែមួយគត់ប៉ុណ្ណោះ។ គ្រូបង្រៀននៅសាលារៀនទាំងអស់ធ្វើតេស្តវាយតម្លៃជាបន្តបន្ទាប់នូវការរៀនសូត្រនៃសិស្សរបស់ខ្លួន នៅក្នុងផ្នែកអក្ខរកម្មនិងលេខនព្វន្ត។ ការធ្វើតេស្ត NAPLAN គឺជាការបង្គ្រប់បន្ថែម ប៉ុន្តែមិនជំនួសឲ្យព័ត៌មានដែលប្រមូលផ្តុំដោយគ្រូបង្រៀនឡើយ។

## របាយការណ៍អំពីសាលារៀន

លទ្ធផលមធ្យមរបស់សាលារៀនសម្រាប់ការធ្វើតេស្ត NAPLAN ត្រូវបានរាយការណ៍តាមវិធីប្រៀបធៀបទូទាំងប្រទេស នៅតាមវ៉ិបសៃ *My School* (www.myschool.edu.au)។ វ៉ិបសៃនេះផ្តល់ជូនមាតាបិតានិងសមាជិកសហគមន៍ នូវព័ត៌មានក្នុងការធ្វើជម្រើសនិងសេចក្តីសម្រេចចិត្តដែលមានការជ្រាបដឹងព័ត៌មាន ដើម្បីជំរុញឲ្យមានការកែលំអសាលារៀន។

ដើម្បីទទួលព័ត៌មានបន្ថែមអំពីវ៉ិបសៃ *My School* សូមទាក់ទង ACARA តាមទូរស័ព្ទលេខ 1300 895 563 ឬតាមរយៈអ៊ីមែល info@myschool.edu.au

## របាយការណ៍របស់សិស្សនីមួយៗ

ទម្រង់នៃរបាយការណ៍ NAPLAN របស់សិស្ស មានលក្ខណៈដូចគ្នា សម្រាប់រដ្ឋនិងដែនដីទាំងអស់របស់អូស្ត្រាលី ហើយត្រូវបានកំណត់ទូទាំងប្រទេសសម្រាប់ការរាយការណ៍នូវសមិទ្ធិផលរបស់សិស្ស ជូនមាតាបិតានិងអ្នកថែទាំទាំងឡាយ។

របាយការណ៍នីមួយៗមានរួមទាំង៖

- ព័ត៌មានរបស់សិស្សនិងសាលារៀន
- ព័ត៌មានអំពីបណ្តាតេស្ត NAPLAN
- ព័ត៌មានអំពីរបៀបអានរបាយការណ៍របស់សិស្ស
- លទ្ធផលនៃសមិទ្ធិផលរបស់សិស្សនីមួយៗ សម្រាប់ការអាន សរសេរបញ្ចុះបញ្ចូល ក្បួនភាសា និងលេខនព្វន្ត នៅលើរង្វាស់ខ្នាតតេស្តវាយតម្លៃ NAPLAN
- ការចង្អុលបង្ហាញសម្រាប់ការធ្វើតេស្តវាយតម្លៃមុខវិជ្ជានីមួយៗ ដែលបង្ហាញនូវលទ្ធផលជាតិជាមធ្យម និងលទ្ធផលរបស់សិស្សធុនកណ្តាល 60% នៃលទ្ធផលទូទាំងប្រទេស
- សេចក្តីពណ៌នាជាលាយលក្ខណ៍អក្សរសម្រាប់ការវាយតម្លៃមុខវិជ្ជានីមួយៗ ដោយប្រាប់ឲ្យដឹងនូវប្រភេទនៃជំនាញទាំងឡាយដែលទទួលការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សា
- តារាងមួយដែលពណ៌នានូវជំនាញដែលសិស្សទំនងជាបង្ហាញនៅក្នុងលំដាប់ក្រុមនីមួយៗ។

## ការអានរបាយការណ៍របស់សិស្សនីមួយៗ

ចំណុចខ្មៅមួយនៅលើរូបក្រាហ្វិកនីមួយៗ តំណាងឲ្យលទ្ធផលរបស់កូនលោកអ្នក។ ជំនាញទាំងពួងពាក់ព័ន្ធនឹងលំដាប់ក្រុមដែលមានចំណុចណាមួយនៅក្នុងនោះ ត្រូវបានពណ៌នានៅទំព័រខាងខ្នងនៃរបាយការណ៍នេះ។ សិស្សដែលទទួលការធ្វើតេស្តវាយតម្លៃសមត្ថភាពសិក្សានៅក្នុងលំដាប់ក្រុមជាក់លាក់ណាមួយ ទំនងជាបានឆ្លើយយ៉ាងត្រឹមត្រូវទៅនឹងសំណួរពាក់ព័ន្ធនឹងជំនាញទាំងឡាយនៅក្នុងលំដាប់ក្រុមនោះ និងនៅក្នុងលំដាប់ក្រុមនីមួយៗដែលនៅពីខាងក្រោម។ លទ្ធផលរបស់កូនលោកអ្នកអាចយកទៅប្រៀបធៀបនឹងលទ្ធផលនៃសិស្សធុនកណ្តាល 60% នៃសិស្សអូស្ត្រាលីទាំងអស់ និង/ឬប្រៀបធៀបនឹងលទ្ធផលជាតិជាមធ្យមសម្រាប់កម្រិតថ្នាក់របស់កូនលោកអ្នក។

## រង្វាស់ខ្នាតវាយតម្លៃ និង ស្តង់ដារជាតិទាបបំផុត

រង្វាស់ខ្នាតវាយតម្លៃ NAPLAN នីមួយៗ ពណ៌នានូវសមិទ្ធិផលរបស់សិស្ស ចាប់ពីថ្នាក់ទី 3 រហូតដល់ថ្នាក់ទី 9 ព្រមជាមួយរង្វាស់ខ្នាតទូទៅមួយ ដែលចែកជាដប់លំដាប់ក្រុម។ លំដាប់ក្រុមទាំងពួងបង្ហាញនូវភាពស្មុគស្មាញខ្លាំងឡើងនៃជំនាញដែលវាយតម្លៃដោយ NAPLAN ។ លំដាប់ក្រុមចំនួនប្រាំមួយ ត្រូវបានប្រើសម្រាប់ការរាយការណ៍អំពីសមត្ថភាពសិក្សារបស់សិស្សនៅកម្រិតថ្នាក់នីមួយៗ។

ស្តង់ដារជាតិទាបបំផុតគឺសម្រាប់លំដាប់ក្រុមមួយនៃកម្រិតថ្នាក់នីមួយៗ និងពណ៌នានូវជំនាញនិងការយល់ដឹងខ្លះដែលសិស្សអាចបង្ហាញជាទូទៅ នៅក្នុងឆ្នាំសិក្សាជាក់លាក់របស់ខ្លួន។ ស្តង់ដារទាំងនេះតំណាងឲ្យជំនាញនិងការយល់ដឹងរឹតតែលំបាកឡើង នៅពេលដែលសិស្សរីកចម្រើនពីថ្នាក់ទី 3 ដល់ថ្នាក់ទី 9។ បើលទ្ធផលរបស់កូនលោកអ្នកស្ថិតនៅក្នុង ឬក្រោមលំដាប់ក្រុមនេះ លោកអ្នកគួរពិភាក្សានូវលទ្ធផលនេះជាមួយនឹងសាលារៀនរបស់កូនលោកអ្នក។

- សម្រាប់ថ្នាក់ទី 3 ស្តង់ដារទាបបំផុតគឺលំដាប់ក្រុមទី 2
- សម្រាប់ថ្នាក់ទី 5 ស្តង់ដារទាបបំផុតគឺលំដាប់ក្រុមទី 4
- សម្រាប់ថ្នាក់ទី 7 ស្តង់ដារទាបបំផុតគឺលំដាប់ក្រុមទី 5
- សម្រាប់ថ្នាក់ទី 9 ស្តង់ដារទាបបំផុតគឺលំដាប់ក្រុមទី 6។

## ឧទាហរណ៍នៃរូបក្រាហ្វិករង្វាស់ខ្នាតវាយតម្លៃ NAPLAN

### ការអាន ថ្នាក់ទី 3




ចំណុចខ្មៅចង្អុលបង្ហាញថា សិស្សថ្នាក់ទី 3 នេះ បានសម្រេចលទ្ធផលមួយនៅក្នុងលំដាប់ក្រុមទី 4 សម្រាប់ការអាន ដែលមានកម្រិតខ្ពស់ជាងលទ្ធផលមធ្យមទូទាំងប្រទេសបន្តិច។ រូបត្រីកោណខ្មៅនេះចង្អុលបង្ហាញនូវលទ្ធផលមធ្យមទូទាំងប្រទេស សម្រាប់សិស្សថ្នាក់ទី 3។ ផ្នែកពណ៌ខៀវខ្ចីបង្ហាញនូវទំហំនៃសមិទ្ធិផលសម្រាប់សិស្សធុនកណ្តាល 60% នៃសិស្សថ្នាក់ទី 3។

### ការសរសេរ ថ្នាក់ទី 5 (បញ្ចុះបញ្ចូល)




ចំណុចខ្មៅចង្អុលបង្ហាញថា សិស្សថ្នាក់ទី 5 នេះ បានទទួលលទ្ធផលមួយនៅក្រោមស្តង់ដារជាតិទាបបំផុត សម្រាប់ការសរសេរ(បញ្ចុះបញ្ចូល)។ មាតាបិតានៃសិស្សដែលទទួលលទ្ធផលដូចនេះ គួរពិភាក្សាជាមួយសាលារៀន។

### លេខនព្វន្ត ថ្នាក់ទី 7




ចំណុចខ្មៅចង្អុលបង្ហាញថា សិស្សថ្នាក់ទី 7 នេះបានសម្រេចលទ្ធផលមួយក្នុងលំដាប់ក្រុមទី 9 សម្រាប់លេខនព្វន្ត ដែលមានកម្រិតខ្ពស់ខ្លាំងជាងលទ្ធផលលេខនព្វន្តភាគច្រើន និងលទ្ធផលមធ្យមទូទាំងប្រទេសសម្រាប់សិស្សថ្នាក់ទី 7។